# Mekong River Commission

P.O. Box 6101, Vientiane 01000, Lao PDR
Telephone: (856-21) 263 263   Facsimile: (856-21) 263 264
Email: mrcs@mrcmekong.org  Website: www.mrcmekong.org


## សេចក្តីប្រកាសព័ត៌មាន

**MRC No. 10/08**

## ការជូនដំណឹងជាមុនអំពីទឹកជំនន់ទន្លេមេគង្គ នឹងត្រូវប្រកាសបានឆាប់រហ័សជាងមុន

**រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨**

ការជូនដំនឹងជាមុនអំពីទឹកជំនន់នៅតាមដងទន្លេមេគង្គ និងដៃទន្លេនេះ អាចនឹងប្រកាសបានឆាប់រហ័សជាងមុន ដោយសារមានការវិនិយោគនៅពេលថ្មីៗនេះ ទៅលើប្រព័ន្ធព្យាករណ៍ប្រចាំតំបន់ តាមរយៈកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយ គ្រោះទឹកជំនន់របស់គណៈកម្មការទន្លេមេគង្គ (Mekong River Commission-MRC) ។

យោងតាមប្រតិភូ ដែលបានមកចូលរួមវេទិកាស្តីពីទឹកជំនន់ប្រចាំឆ្នាំលើកទី៦ ដែលបានធ្វើឡើងនៅក្រុងភ្នំពេញកាលពីថ្ងៃទី២៧-២៨ ខែឧសភានេះថា ប្រជាជនដែលងាយរងគ្រោះពីទឹកជំនន់នៅអាងទន្លេមេគង្គក្រោម នឹងទទួលបានការជូនដំនឹងជាមុនអំពីព្រឹត្តិការណ៍ជន់លិចកាន់តែប្រសើរជាងមុន ក្នុងពេលឆាប់ៗនេះ ។ ការកែលម្អផ្នែកបច្ចេកវិទ្យា និងកិច្ចសហប្រតិ-បត្តិការក្នុងចំណោមរដ្ឋជាសមាជិករបស់ MRC រួមមាន កម្ពុជា ឡាវ ថៃ និង វៀតណាម ព្រមទាំងសមត្ថភាពក្នុងការប្រមូល និងវិភាគទិន្នន័យ នៅតាមប្រទេសនីមួយៗកាន់តែប្រសើរឡើង មានន័យថា ការជូនដំណឹងជាមុនជាអំពីការលទ្ធផលនៃព្យាករណ៍ទឹកជំនន់ ត្រូវកើនពី ៥ថ្ងៃ ទៅ ១០ថ្ងៃ នៅក្នុងរដូវវស្សា ឆ្នាំ២០០៩ ។

ក្រោយព្រឹត្តិការណ៍ប្រកបដោយសោកនាដកម្មនាពេលថ្មីៗ នៅប្រទេសភូមា ភាពចាំបាច់ក្នុងការវិភាគធាតុអាកាស និងលំនាំនៃការវិវឌ្ឍធាតុអាកាសដោយប្រុងប្រយ័ត្ន ព្រមទាំងការចែកចាយព័តិមាន ពុំសូវមានលក្ខណៈច្បាស់លាស់ដូច្នេះទេ ពីមុនមក ។ ឯកឧត្តម ស៊ីន នីនី អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានជម្រាបអង្គប្រជុំថា កំណើនប្រជាពលរដ្ឋដ៏ឆាប់រហ័សគួបផ្សំនឹងការធ្វើនគរូបនីយកម្ម និងការផ្លាស់ប្តូរនៃការប្រើប្រាស់ដីធ្លី និងរូបសាស្ត្រទន្លេ មានន័យថា សមត្ថភាពផ្តល់ការជូនដំនឹងជាមុនអំពីទឹកជំនន់ ត្រូវការការកែលម្អអោយកាន់តែប្រសើរឡើងថែមទៀត ។ អនុលោមតាមចំណុចនេះ ប្រទេសទាំងបួនបាន និងកំពុងធ្វើការជាមួយ MRC ដើម្បីបង្កើតឡើងប្រព័ន្ធថ្មីមួយដែលអាច ផ្តល់ការព្យាករណ៍ទឹកជំនន់សំរាប់រយៈពេលមធ្យមបាន ។

វេទិកាប្រចាំឆ្នាំ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់របស់ MRC នេះ ត្រូវបានរៀបចំឡើង ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្រ្ត និងភស្តុភារ ក្នុងបំណងដើម្បីធានាអោយប្រជាជននៅតាមដងទន្លេមេគង្គ និងដៃទន្លេនេះ រងគ្រោះតិចតួចពីទឹកជំនន់ ផ្ទុយទៅវិញ នៅតែអាចបន្តទទួលផលប្រយោជន៏វិជ្ជមានពីទឹកជំនន់ប្រចាំឆ្នាំ ។ វេទិកាឆ្នាំនេះត្រូវបានប្រារព្ធធ្វើឡើងក្រោមប្រធានបទ "វិធីសាស្រ្តចម្រុះ និងប្រព័ន្ធដែលអាចអនុវត្តបានសម្រាប់ព្យាករណ៍ទឹកជំនន់រយៈពេលមធ្យម និងការជូនដំនឹងជាមុននៅក្នុងអាងទន្លេមេគង្គ" ។

ក្នុងរយៈពេលពីរថ្ងៃបន្ទាប់ទៀតនេះ វេទិកានឹងផ្តល់ឱកាសអោយប្រតិភូមកពីប្រទេសទាំងបួន ព្រមទាំងប្រទេសចិន ភូមា និងតំណាងមកពីអង្គការអន្តរជាតិ និងសង្គមស៊ីវិល ដើម្បីចែករំលែកទស្សនៈ និងបទពិសោធន៍ ។ យោងតាមនាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC គឺលោក Jeremy Bird ថាព្រឹត្តិការណ៍នេះ ជួយបង្កើនកម្រិតនៃការត្រៀមបង្ការសម្រាប់គ្រោះទឹកជំនន់ផងដែរ ។ លោកបានមានប្រសាសន៍ថា "ចំណុចផ្តោតធំបំផុតរបស់យើង គឺការផ្តល់សេវាគ្រប់គ្រងទឹកជំនន់ប្រកបដោយគុណភាពដល់ប្រជាជននៅក្នុងអាងទន្លេមេគង្គ ។ យើងមិនមែន ផ្តោតតែទៅលើមជ្ឈមណ្ឌលទឹកជំនន់ដែលកំពុងតែធ្វើការសាកល្បងប្រព័ន្ធថ្មី ដែលនឹងផ្តល់សមត្ថភាពព្យាករណ៍ទឹកជំនន់ កាន់តែមានភាពជាក់លាក់ប៉ុណ្ណោះទេ ប៉ុន្តែយើងក៏កំពុងតែធ្វើការដើម្បីពង្រឹងទំនាក់ទំនងជាមួយស្ថាប័នថ្នាក់ជាតិ និងមូលដ្ឋាន ដែលអាចផ្សព្វផ្សាយព័ត៌មាននេះដល់ប្រជាជនដែលរស់នៅតាមតំបន់ដែលងាយទទួលរងទឹកជំនន់ផងដែរ" ។

• **សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង : Aiden Glendinning, មន្ត្រីទំនាក់ទំនងស្តីទី ។ ទូរស័ព្ទលេខ : (៨៥៦) ២១ ២៦៣ ២៦៣ លេខភ្ជាប់ : ៤៧០៣ ។ ទូរស័ព្ទចល័ត : (៨៥៦) ២០ ៩៥៩ ៩១៣៩ ទូរសារ : (៨៥៦-២១) ២៦៣ ២៦៤ អ៊ីមែល :**
**aiden@mrcmekong.org**